**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**
**ឯកឧត្តម សៀច បណ្ណាសិទ្ធ**

*ឯកឧត្តមជាទីរាប់អាន*

ភរិយាខ្ញុំ និងរូបខ្ញុំ ព្រមទាំងក្រុមគ្រួសារបានទទួលដំណឹងដ៏ក្រៀមក្រំអំពីការទទួលមរណភាព ឯកឧត្តម **សៀច បណ្ណាភា** ដែលជាបិតាបង្កើតរបស់ឯកឧត្តមក្នុងជន្មាយុ ៨៩ ឆ្នាំ ដោយជរាពាធ ។

មរណភាពឯកឧត្តម **សៀច បណ្ណាភា** គឺជាការបាត់បង់បិតា ជីតា ប្រកបដោយព្រហ្មវិហារធម៌មួយរូបដែលបានចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានកូនចៅប្រកបដោយគន្លងធម៌ ។ មរណភាព ឯកឧត្តម **សៀច បណ្ណាភា** គឺជាការបាត់បង់កុលបុត្រដ៏ឆ្នើមរបស់ជាតិ និងប្រជាជនកម្ពុជា ដែលបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុ ជាតិ សាសនា ព្រះមហាក្សត្រ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំនិងរូបខ្ញុំសូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយឯកឧត្តម លោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឯកឧត្តម **សៀច បណ្ណាភា** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តមទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*ថ្ងៃ សុក្រ ១២ រោច ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨*

ហ៊ុន សែន